## រឿងទី៣៖ ដាវីឌ និងយ៉ូណាថាន

**ខគម្ពីរ៖ ១សាំយូអែល២០៖៤**

នោះយ៉ូណាថាននិយាយនឹងដាវីឌថា៖ «ការអ្វីដែលចិត្តអ្នកប្រាថ្នាចង់បាន នោះខ្ញុំនឹងសម្រេចឲ្យ»

ដាវីឌបានយកឈ្នះលើកូលីយ៉ាតមេទ័ពភីលីស្ទីន បន្ទាប់មកគាត់បានចូលទៅរស់នៅក្នុងវាំងរបស់ស្តេចសូល។
ស្តេចសូលមានបុត្រាម្នាក់ឈ្មោះយ៉ូណាថាន។ យ៉ូណាថានចូលចិត្តដាវីឌដែលជាមនុស្សក្លាហានខ្លាំងណាស់។
ពួកគេទាំងពីរជួបគ្នាភ្លាម ក៏ក្លាយជាមិត្តនិងគ្នាភ្លាម។
យ៉ូណាថានបានដោះសម្លៀកបំពាក់របស់ខ្លួនដែលស្រឡាញ់ខ្លាំងជាងគេ យកទៅបំពាក់ឱ្យដាវីឌ ហើយបានប្រគល់ អាវសឹក ដាវ ធ្នូ និងខ្សែក្រវាត់របស់ខ្លួនទៅដាវីឌ ជាអំណោយ។



យ៉ូណាថាន និងដាវីឌបានសន្យានិងគ្នាថា នឹងក្លាយជាមិត្តល្អនិងគ្នាជារៀងរហូត។
យ៉ូណាថាន និងដាវីឌបានក្លាយជាមិត្តនិងគ្នា ពួកគេស្រឡាញ់ និងមើលថែការពារគ្នាទៅវិញទៅមក។
មានថ្ងៃមួយ ស្តេចសូលនិងដាវីឌបានត្រឡប់មកពីសមរភូមិជាមួយគ្នា។
នៅតាមផ្លូវ មានប្រជារាស្ត្រជាច្រើនចេញមកទទួលពួកគេដោយច្រៀងអបអរ។
«ព្រះបាទសូលប្រហារបានរាប់ពាន់នាក់ រីឯដាវីឌប្រហារបានរាប់ម៉ឺននាក់»
ពាក្យទាំងនេះ បានធ្វើឱ្យស្តេចសូលខ្ញាល់ជាខ្លាំង។
ស្តេចសូល ខ្ញាល់ព្រោះប្រជារាស្ត្រស្រឡាញ់ចូលចិត្តដាវីឌជាងខ្លួន ហើយក៏កាន់តែស្អប់ដាវីឌខ្លាំងឡើងៗ។
ស្តេចសូល មានចិត្តចង់សម្លាប់ដាវីឌ។ យ៉ូណាថានបានដឹងការពិតនេះ គាត់មានការព្រួយបារម្ភពីដាវីឌជាខ្លាំង។
ដូច្នេះ យ៉ូណាថានក៏ចូលទៅនិយាយជាមួយស្តេចសូលទាំងក្លាហានថា៖
«បិតាអើយ ហេតុអ្វីបានជាទ្រង់ចង់សម្លាប់មិត្តទូលបង្គំដូច្នេះ? តើដាវីឌមិនមែនច្បាំងឈ្នះកូលីយ៉ាតទេឬអី?
គាត់គឺជាទាហានដ៏ក្លាហាន និងស្មោះត្រង់»។
ស្តេចសូលមានការខ្មាស់អៀនជាខ្លាំង ដូច្នេះ ទ្រង់បានសន្យាថា៖
«បុត្រនិយាយត្រូវហើយ យើងនឹងមិនសម្លាប់ដាវីឌជាដាច់ខាត»។



ប៉ុន្តែ មានថ្ងៃមួយ ស្តេចសូលបានគប់លំពែងទៅដាវីឌដែលកំពុងលេងពិណ។ ដាវីឌបានរត់គេចខ្លួនទាំងយប់។
ស្តេចសូលបានដឹងថាដាវីឌបាត់ខ្លួន។ ស្តេចសូលមិនពេញចិត្តចំពោះយ៉ូណាថានដែលបានជួយដាវីឌទេ។
ទ្រង់បានខ្ញាល់និងយ៉ូណាថានជាខ្លាំង។ ស្តេចសូលបានបង្គាប់ឱ្យទាហានដេញតាមដាវីឌ។
ពេលស្តេចសូលចង់សម្លាប់ដាវីឌ យ៉ូណាថានបានឱ្យដាវីឌលាក់ខ្លួននៅខាងក្រោយថ្មដ៏ធំមួយ។
ទោះបីស្តេចសូលស្អប់ចង់សម្លាប់ដាវីឌយ៉ាងណាក៏ដោយ ក៏ទ្រង់មិនស្អប់យ៉ូណាថានដែរ។
យ៉ូណាថាន បានចេញទៅកន្លែងដែលខ្លួនបានឱ្យដាវីឌលាក់ខ្លួន ហើយបាននិយាយទៅដាវីឌថា៖ «ដាវីឌ មើលទៅបិតាចង់សម្លាប់អ្នកមែនទែនហើយ ចូរប្រញាប់រត់ទៅ»។
ដាវីឌ និងយ៉ូណាថានបានឱបគ្នា។
ពេលនេះដល់ពេលយើងត្រូវបែកគ្នាហើយ ប៉ុន្តែអ្នកទាំងពីរនេះ នៅតែជាមិត្តល្អនឹងគ្នារហូត។



**សកម្មភាពទី១** សូមកាត់អំណោយដែលយ៉ូណាថានបានឱ្យដាវីឌ រួចបំពាក់ឱ្យដាវីឌ។ **សម្ភារៈ៖ កន្ត្រៃ កាវ**











រូបភាពរួចរាល់



**សកម្មភាពទី២** សូមឆ្លើយសំណួរខាងក្រោម។

a. តើនរណាជាមិត្តជិតស្និទ្ធស្នាលបំផុតរបស់ដាវីឌ?

------------------------------------------------------------------------

b. តើយ៉ូណាថានបានឱ្យអ្វីជាអំណោយដល់ដាវីឌ?

------------------------------------------------------------------------

c. សូមអានគម្ពីរ ១សាំយូអែល ១៨:៦-១៦ រួចឆ្លើយសំណួរ។ តើហេតុអ្វីបានជាសូលព្យាយាមសម្លាប់ដាវីឌ?

------------------------------------------------------------------------

d. តើដាវីឌនិងយ៉ូណាថានបានបង្រៀនយើងអ្វីខ្លះពីអ្វីដែលយើងបានរៀននៅថ្ងៃនេះ?

------------------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (១សាំយូអែល២០:៤)

> នោះយ៉ូណាថាននិយាយនឹងដាវីឌថា៖ «ការអ្វីដែលចិត្តអ្នកប្រាថ្នាចង់បាន នោះខ្ញុំនឹងសម្រេចឲ្យ»